# ការជូនដំណឹងអំពីលទ្ធភាពនៃការប៉ះពាល់សម្រាប់សាលា K-12

| ឈ្មោះបុគ្គលដែលមានសក្តានុពលភាពនឹងប៉ះពាល់ | ឈ្មោះសាលារៀន | កាលបរិច្ឆេទនៃការប៉ះពាល់ |
|---|---|---|

អ្នកត្រូវបានគេកំណត់ថាអ្នកមានលទ្ធភាពប្រឈមមុខនឹងអ្នកមានការឆ្លងមេរោគកូវីដ-១៩ នៅសាលា។

ការដាក់ឱ្យនៅដាច់ដោយឡែកពីគេបន្ទាប់ពីការប៉ះពាល់នៅក្នុងសាលា មិនថាស្ថិតក្នុងស្ថានភាពនៃការទទួលថ្នាំបង្ការបែបណានោះ គឺមិនត្រូវបានទាមទារនោះទេ។

តើនេះមានន័យថាយ៉ាងម៉េច?

អ្នកអាចបន្តនៅសាលា លុះត្រាតែអ្នកមានរោគសញ្ញា ឬធ្វើតេស្តឃើញវិជ្ជមានជំងឺកូវីដ-១៩។ កាលដែលកំពុងមាន សក្តានុពលភាព ដែលនឹងប៉ះពាល់ជាមួយអ្នកដែលមានជំងឺកូវីដ-១៩ មិនមានន័យថា អ្នកនឹងក្លាយទៅជាអ្នក មានឆ្លងមេរោគនោះទេ។ ការសិក្សាជាច្រើនបានបង្ហាញថា អត្រាឆ្លងដែលស្ថិតនៅក្នុងការកំណត់របស់ សាលារៀន ជាធម្មតាទាបជាង ឬស្រដៀងគ្នាទៅនឹងកម្រិតនៃការឆ្លងនៅក្នុងសហគមន៍ នៅពេលដែលមានយុទ្ធសាស្ត្រការពារជាច្រើនផ្សេងៗគ្នាត្រូវបានអនុវត្ត។

អនុវត្តតាមការណែនាំរបស់សុខភាពសាធារណៈ ដើម្បីជួយទប់ស្កាត់ការរីករាលដាលនៃ ជំងឺកូវីដ-១៩ ទាំងនៅក្នុងផ្ទះ និងនៅក្នុងសាលារៀន។

## អនុសាសន៍សុខភាពសាធារណៈ

- សូមធ្វើតេស្ត  យ៉ាងហោចណាស់ ៥ ថ្ងៃ បន្ទាប់ពីការទំនាក់ទំនងចុងក្រោយរបស់អ្នកជាមួយអ្នកដែលមាន ជំងឺកូវីដ-១៩ ទោះបីជាអ្នកមិនមានរោគសញ្ញាក៏ដោយ។
    - ប្រើឧបករណ៍ធ្វើតេស្តដោយខ្លួនឯង ឬ
    - ស្វែងរកទីតាំងធ្វើតេស្ត ៖
        - ធ្វើតេស្តជំងឺកូវីដ-១៩ តាមកម្មវិធីរបស់ស្រុក
        - កន្លែងធ្វើតេស្តបង្អែករបស់សហគមន៍សម្រាប់ជំងឺកូវីដ-១៩
- តាមដានរោគសញ្ញា។
    - ប្រសិនបើអ្នកមានរោគសញ្ញា សូមដាក់ឱ្យនៅដាច់ដោយឡែក និងធ្វើតេស្តរកជំងឺកូវីដ-១៩ ជាបន្ទាន់។
    - ប្រសិនបើអ្នកធ្វើតេស្តវិជ្ជមាន អ្នកត្រូវតែនៅដាច់ដោយឡែកពីគេយ៉ាងហោចណាស់ ៥ ថ្ងៃ។ ធ្វើតាមការកំណត់ ការដាក់ឱ្យនៅដាច់ដោយឡែក និងការគណនាការដាក់ដាច់ដោយឡែករបស់ CDC ដើម្បីកំណត់រយៈពេលដែល ត្រូវដាក់ឱ្យនៅដាច់ដោយឡែក។
    - ទាក់ទងអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកភ្លាមៗ ប្រសិនបើអ្នកទំនងជាឈឺខ្លាំងពីជំងឺកូវីដ-១៩។ អ្នកអាចរកបាន ការព្យាបាលប្រកបដោយប្រសិទ្ធភាព។
- ប្រសិនបើអ្នកមានសំណួរបន្ថែម សូមចូលទៅកាន់គេហទំព័រ https://hawaiicovid19.com/translations/ សម្រាប់ ការណែនាំ ដែលមាន ២១ ភាសា។
- អ្នកអាចទាក់ទងនាយកដ្ឋានសុខភាពរដ្ឋ Hawai`i តាមរយៈលេខ (៨០៨) ៥៨៦-៨៣៣២ ប្រសិនបើអ្នកមានសំណួរបន្ថែម។